**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..៣៧៧២៩....អពដ

L202511180237TD3526

ថ្ងៃអង្គារ ១២កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការលុបចោលអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ របស់ក្រុមហ៊ុន អេចធី & ភី ផាតនើរ ឯ.ក

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅជ្រាបថា អគ្គនាយកដ្ឋានពន្ធដារបានសម្រេចលុបចោលអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន **អេចធី & ភី ផាតនើរ ឯ.ក** ( HT & P PARTNERS CO., LTD. ) លេខអត្តសញ្ញាណកម្មសារពើពន្ធ K010-901703637 លេខអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារ TA201709002 គិតចាប់តាំងពីកាលបរិច្ឆេទនៃលិខិតជូនដំណឹងនេះតទៅ។ តាមរយៈការសម្រេចនេះ ក្រុមហ៊ុនត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបដល់លោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យ និងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីជាអភិបាលក្រុមហ៊ុន អ្នកជាប់ពន្ធ និងសាធារណជនទូទៅ ជ្រាបជាព័ត៌មាន។

**អគ្គនាយកដ្ឋានពន្ធដារ**